# លិខិតុបករណ៍
# អង្គការសហប្រជាជាតិ
# ស្តីពីចៅក្រម ព្រះរាជអាជ្ញា
# និង មេធាវី

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

UNIVERSAL DECLARATION OF HUMAN RIGHTS

Dignity and justice for all of us

United Nations Human Rights

OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS

Cambodia Country Office - Phnom Penh - Cambodia

# លិខិតុបករណ៍អន្តរជាតិស្តីពីចៅក្រម
# ព្រះរាជអាជ្ញា និងមេធាវី

*គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ*

*(១៩៨៥)*

*គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា*

*(១៩៩០)*

*គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី*

*(១៩៩០)*

បោះពុម្ពផ្សាយដោយការិយាល័យ

ឧត្តមស្នងការអង្គការសហប្រជាជាតិនៅកម្ពុជា

មករា ២០០៧

# លិខិតតុបករណ៍អន្តរជាតិស្តីពីចៅក្រម ព្រះរាជអាជ្ញា និងមេធាវី

## អារម្ភកថា

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានតំកល់គោលការណ៍សមភាពចំពោះមុខច្បាប់ ការសន្មត់ជាមុនថាគ្មានទោស សិទ្ធិទទួលបាននូវការជំនុំជំរះប្រកបដោយយុត្តិធម៌ និងជាសាធារណៈ ដោយតុលាការមួយឯករាជ្យ មិនលំអៀង និងមានសមត្ថកិច្ច ដែលត្រូវបានបង្កើតឡើងដោយច្បាប់ ត្រូវចាត់ទុកជាសិទ្ធិមនុស្សជាសារវ័ន្ត។ សិទ្ធិទាំងនេះ ត្រូវបានបរិយាយជាបន្តបន្ទាប់នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនិងសន្ធិសញ្ញាអន្តរជាតិដទៃទៀតដែលត្រូវបានដាក់បញ្ចូលក្នុងច្បាប់កម្ពុជាតាមរយៈមាត្រា៣១ និង៣៨ នៃរដ្ឋធម្មនុញ្ញ។

មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តគោលការណ៍ និងគោលការណ៍ណែនាំបន្ថែមដែលអនុវត្តចំពោះសមាជិកនៃវិជ្ជាជីវៈច្បាប់ ដើម្បីឱ្យពួកគេ អាចធានាថា ការរៀបចំ និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ៖

*គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ (១៩៨៥)*

*គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា (១៩៩០)*

*គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី (១៩៩០)*

គោលការណ៍ និងគោលការណ៍ណែនាំទាំងនេះត្រូវបានដាក់បញ្ចូលដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងច្បាប់កម្ពុជាកាលពីឆ្នាំ១៩៩២ តាមរយៈមាត្រា១ និងមាត្រា៧៤ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលដែលគេស្គាល់ជាទូទៅថា ច្បាប់អ៊ុនតាក់ ហើយត្រូវបានអះអាងជាបន្តបន្ទាប់នៅក្នុងច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធ ។

**គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ** បានបង្កើតបទដ្ឋានជាមូលដ្ឋាន ដើម្បីធានាឯករាជ្យភាព និងអនាគតិនៃតុលាការ គ្មានការជ្រៀតជ្រែកដែលមិនសមស្រប និងគ្មានយុត្តិកម្ម សេរីភាពក្នុងការសំដែងមតិ និងការបង្កើតសមាគម លក្ខណៈសម្បត្តិ ការជ្រើសរើស និងការបណ្តុះបណ្តាល លក្ខខណ្ឌការងារ និងមុខតំណែង ការសំងាត់ខាងវិជ្ជាជីវៈ និងអភ័យឯកសិទ្ធិនិងការដាក់វិន័យ ការព្យួរការងារ និងការដកចេញពីមុខតំណែង ។

មាត្រា១២៨ នៃរដ្ឋធម្មនុញ្ញ ធានាឯករាជ្យភាពនៃអំណាចតុលាការកម្ពុជាដែលចែងថា "ត្រូវធានា រក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ។" យោងតាម មាត្រា១៣២ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យភាពនៃអំណាចតុលាការ ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

**គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា** បង្កើតវិធាននានាដើម្បីធានាថា ព្រះរាជអាជ្ញាបំពេញការទទួលខុសត្រូវរបស់ខ្លួន ចំពោះការគោរពដ៏សមគួរក្នុងការអនុវត្តន៍តាមវិធានសិទ្ធិមនុស្សអន្តរជាតិ ដើម្បីរួមវិភាគទានដល់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដ៏ត្រឹមត្រូវ និងស្មើភាពមួយ និងការការពារប្រជាពលរដ្ឋ ពីបទល្មើសប្រកបដោយប្រសិទ្ធភាព ។ គោលការណ៍ណែនាំនេះថ្លែងពីលក្ខណៈសម្បត្តិ ការជ្រើសរើស និងការបណ្តុះបណ្តាល ឋានៈនិងលក្ខខណ្ឌនៃសេវាកម្ម សេរីភាពក្នុងការសំដែងមតិ និងការបង្កើតសមាគម តួនាទីក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ មុខការឆន្ទាគតិ ជំរើសផ្សេងៗក្នុងការធ្វើបណ្តឹងអាជ្ញា ទំនាក់ទំនងជាមួយក្រសួង ឬស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល និងដំណើរការដាក់ទណ្ឌកម្មផ្នែកវិន័យ។ ព្រះរាជអាជ្ញា ត្រូវគោរព និងខិតខំយកអស់ពីសមត្ថភាពរបស់ខ្លួនដើម្បីការពារ និងប្រឆាំងយ៉ាងសកម្ម ចំពោះការរំលោភលើ

គោលការណ៍ណែនាំទាំងនេះ។

ស្របតាមគោលការណ៍ណែនាំទាំងនេះ មាត្រា១២៩ និងមាត្រា១៣១ នៃរដ្ឋធម្មនុញ្ញ ធ្វើការបែងចែកដាច់ស្រឡះ រវាងមុខងារអយ្យការ និងមុខងារចៅក្រម។ គោលការណ៍ណែនាំទាំងនេះ បញ្ជាក់ថា ព្រះរាជអាជ្ញា ត្រូវយកចិត្តទុកដាក់បំផុត ចំពោះការចោទប្រកាន់បទល្មើសទាំងឡាយ ដែលបានប្រព្រឹត្តដោយមន្ត្រីសាធារណៈ ជាពិសេស អំពើពុករលួយ ការរំលោភអំណាច ការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស និងបទល្មើសដទៃទៀតដែលច្បាប់អន្តរជាតិបានទទួលស្គាល់។

**គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី** ទទួលស្គាល់ថា ការទទួលបានប្រកបដោយប្រសិទ្ធភាពពីសេវាកម្មច្បាប់ដែលបានផ្តល់ដោយវិជ្ជាជីវៈច្បាប់ឯករាជ្យមួយ គឺជាតំរូវការមុនគេ សំរាប់ការការពារយ៉ាងពេញលេញ ដល់សិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត រួមទាំងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឬសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលមនុស្សគ្រប់រូប មានសិទ្ធិទទួលបាន។ គោលការណ៍ជាមូលដ្ឋាននេះ ថ្លែងពីសិទ្ធិទទួលបានមេធាវី និងសេវាកម្មច្បាប់ ការការពារពិសេសក្នុងរឿងក្តីយុត្តិធម៌ព្រហ្មទណ្ឌ លក្ខណៈសម្បត្តិ និងការបណ្តុះបណ្តាល តួនាទីនិងការទទួលខុសត្រូវរបស់មេធាវី ការ

ធានាចំពោះដំណើរការមេធាវី និងសេរីភាពនៃការសំដែងមតិ និងការបង្កើតសមាគម ។

គោលការណ៍ទាំងនេះ ក៏ទទួលស្គាល់តួនាទីដ៏សំខាន់របស់សមាគមវិជ្ជាជីវៈមេធាវី ក្នុងការលើកកំពស់បទដ្ឋាន និងបញ្ញត្តក្រមសីលធម៌វិជ្ជាជីវៈ ការការពារសមាជិករបស់ខ្លួនពីការចោទប្រកាន់ និងការរិតត្បិតមិនសមស្រប និងការរំលោភបំពានផ្សេងៗ ការផ្តល់សេវាកម្មច្បាប់ដល់ជនទាំងឡាយដែលត្រូវការសេវាកម្មនេះ និងសហការជាមួយរដ្ឋាភិបាល និងស្ថាប័នដទៃទៀត ដើម្បីបុព្វហេតុយុត្តិធម៌ និងផលប្រយោជន៍សាធារណៈ ។ ស្របតាមមាត្រា១នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី វិជ្ជាជីវៈច្បាប់ក្នុងប្រទេសកម្ពុជា គឺជាវិជ្ជាជីវៈមួយឯករាជ្យនិងស្វយ័ត ពាក់ព័ន្ធដល់ការផ្តល់សេវាកម្មយុត្តិធម៌ ហើយអាចអនុវត្តទៅបានតែក្នុងក្របខ័ណ្ឌនៃសមាគមមេធាវី ។

នៅក្នុងក្របខ័ណ្ឌ នៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ **អ្នករាយការណ៍ពិសេសទទួលបន្ទុកឯករាជ្យភាពនៃចៅក្រម និងមេធាវី** តាមឃ្លាំមើលការអនុវត្តន៍គោលការណ៍អន្តរជាតិទាំងនេះ ។

ការិយាល័យឧត្តមស្នងការ
អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
ប្រចាំកម្ពុជា
ខែធ្នូ ឆ្នាំ២០០៦

# គោលការណ៍ជាមូលដ្ឋាន
# ស្ដីពីឯករាជ្យភាពរបស់តុលាការ

*ត្រូវបានអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ស្ដីពី ការបង្ការបទល្មើស និងការប្រព្រឹត្តលើជនល្មើសដែលបានប្រារព្ធធ្វើឡើង នៅទីក្រុងមីលែន ចាប់ពីថ្ងៃទី២៦ ខែសីហា ដល់ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៨៥ ហើយត្រូវបានតំកល់ដោយសេចក្ដីសំរេចចិត្តលេខ៤០/៣២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និងសេចក្ដីសំរេចចិត្តលេខ៤០/១៤៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥ របស់មហាសន្និបាត អ.ស.ប ។*

*ដោយហេតុថា* នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ប្រជាពលរដ្ឋគ្រប់ជាតិសាសន៍ នៅលើពិភពលោក បានអះអាងពីការប្ដេជ្ញាចិត្តរបស់ខ្លួនថា នឹងបង្កើតនូវលក្ខខណ្ឌនានាដែលអាចរក្សាបាននូវយុត្តិធមិ ដើម្បីសំរេចនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការលើកស្ទួយ និងលើកទឹកចិត្តដល់ការគោរពសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត ដោយគ្មានការរើសអើងណាមួយឡើយ ។

*ដោយហេតុថា* សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស តំកល់ទុកជាពិសេសនូវគោលការណ៍មួយចំនួន ដូចជា គោលការណ៍សមភាពចំពោះមុខច្បាប់ គោលការណ៍ស្ដីពីការសន្មត់ជាមុនថាគ្មានទោស គោលការណ៍ស្ដីពីសិទ្ធិទទួលបាននូវការជំនុំជំរះក្ដីដ៏ត្រឹមត្រូវ និងជាសាធារណៈ ដោយតុលាការមួយដែលមានសមត្ថកិច្ច មានឯក

រាជ្យ និងមិនលំអៀង ហើយដែលតុលាការនេះត្រូវបានបង្កើតឡើងដោយច្បាប់ ។

*ដោយហេតុថា* កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាទាំងពីរនេះធានានូវការអនុវត្តន៍សិទ្ធិទាំងនោះ ហើយលើសពីនេះទៅទៀត កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ធានាបន្ថែមទៀត ពីសិទ្ធិទទួលបាននូវការជំនុំជំរះក្តី ដោយគ្មានការពន្យាពេលមិនសមហេតុផលឡើយ ។

*ដោយហេតុថា* ជាញឹកញាប់ នៅមានចន្លោះមួយ រវាងទស្សនៈជាគន្លឹះ ដែលនៅពីក្រោយគោលការណ៍ទាំងនេះ និងស្ថានការណ៍ពិត ។

*ដោយហេតុថា* ការរៀបចំ និងការគ្រប់គ្រងយុត្តិធម៌ នៅតាមបណ្តាប្រទេសនានា ត្រូវតែធ្វើតាមគោលការណ៍ទាំងនោះ ហើយត្រូវខិតខំប្រឹងប្រែងធ្វើការបកស្រាយគោលការណ៍ទាំងនេះ ឱ្យក្លាយជាការពិតយ៉ាងពេញលេញ ។

*ដោយហេតុថា* វិធាននានា ដែលកំពុងប្រើប្រាស់ក្នុងតុលាការ គួរតែមានទិសដៅធ្វើឱ្យចៅក្រមអាចអនុវត្តតាមគោលការណ៍ទាំងនោះបាន ។

*ដោយហេតុថា* ចៅក្រមជាអ្នកទទួលខុសត្រូវក្នុងការចេញ

សេចក្តីសំរេចចុងក្រោយលើអាយុជីវិត សេរីភាព សិទ្ធិ កាតព្វកិច្ច និង ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ។

*ដោយហេតុថា* សមាជលើកទី៦របស់អ.ស.ប.ស្តីអំពីការបង្ការបទល្មើស និងការប្រព្រឹត្តទៅលើជនល្មើស តាមសេចក្តីសំរេចរបស់ខ្លួនលេខ១៦ បានអំពាវនាវឱ្យគណៈកម្មាធិការគ្រប់គ្រង និងបង្ការបទឧក្រិដ្ឋ ដាក់បញ្ចូលទៅក្នុងចំណោមបញ្ហាអាទិភាពរបស់ខ្លួន នូវការតាក់តែងគោលការណ៍ណែនាំទាំងឡាយ ដែលទាក់ទងនឹងឯករាជ្យភាពរបស់ចៅក្រម ព្រមទាំងការជ្រើសរើស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឋានៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ។

*ដោយហេតុថា* នេះជាការប្រពៃណាស់ដែលគេត្រូវយកចិត្តទុកដាក់គិតគូរជាដំបូងពីតួនាទីរបស់ចៅក្រម ក្នុងទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ និងពីសារៈសំខាន់នៃការជ្រើសរើស ការបណ្តុះបណ្តាល និងក្រមសីលធម៌របស់ចៅក្រម ។

គោលការណ៍ជាមូលដ្ឋានដូចមានចែងខាងក្រោមនេះត្រូវបានតាក់តែងឡើង ដើម្បីជួយរដ្ឋជាសមាជិកនានា ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដើម្បីធានា និងលើកស្ទួយនូវឯករាជ្យភាពរបស់តុលាការ ហើយរដ្ឋាភិបាលទាំងឡាយ គួរធ្វើការពិចារណា និងគោរពតាម ក្នុងក្របខ័ណ្ឌនៃនីតិកម្មជាតិ និងការអនុវត្តន៍ជាក់ស្តែងរបស់ខ្លួន ហើយគួរតែត្រូវទាញការចាប់អារម្មណ៍របស់ចៅក្រម មេធាវី សមាជិកនៃអង្គនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ និងសាធារណៈជនជាទូទៅ ។

គោលការណ៍ណែនាំនេះ ត្រូវបានតាក់តែងឡើងជាសំខាន់ សំរាប់ចៅក្រមវិជ្ជាជីវៈ ក៏ប៉ុន្តែគោលការណ៍ទាំងនេះ ក៏អនុវត្តបានដោយស្មើភាពគ្នា ចំពោះចៅក្រមទាំងឡាយដែលធ្វើការក្រៅក្របខ័ណ្ឌតាមការសមស្រប ។

## ឯករាជ្យភាពរបស់តុលាការ

១- រដ្ឋត្រូវធានានូវឯករាជ្យភាពរបស់តុលាការ ហើយឯករាជភាពនេះត្រូវតែតំកល់នៅក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់ជាតិ។ នេះគឺជាកាតព្វកិច្ចរបស់ស្ថាប័នរដ្ឋ និងស្ថាប័នដទៃទៀតទាំងអស់ ក្នុងការគោរព និងប្រតិបត្តិតាមឯករាជ្យភាពរបស់តុលាការ។

២- តុលាការ ត្រូវសំរេចរឿងក្តីទាំងអស់ នៅចំពោះមុខខ្លួនដោយមិនលំអៀង ដោយឈរលើមូលដ្ឋាននៃអង្គហេតុ និងអង្គច្បាប់ ដោយមិនមានការដាក់កំហិត ការប្រើឥទ្ធិពលមិនត្រឹមត្រូវ ការអន្ទងការកៀបសង្កត់ ការគំរាមកំហែង ឬការជ្រៀតជ្រែកទោះដោយផ្ទាល់ ឬដោយប្រយោលពីមជ្ឈដ្ឋានណាមួយ ឬដោយមូលហេតុណាមួយក៏ដោយ ។

៣- តុលាការ ត្រូវមានយុត្តាធិការ លើគ្រប់រឿងក្តីទាំងអស់ដែលមានចរិតជាការវិនិច្ឆ័យ ហើយត្រូវមានអំណាចពេញលេញដើម្បីសំរេចរឿងក្តីណាមួយដែលបានប្តឹងសុំឱ្យតុលាការសំរេច នៅក្នុង

ដែនសមត្ថកិច្ចរបស់ខ្លួន តាមច្បាប់កំណត់ ។

៤- មិនត្រូវឱ្យមានការជ្រៀតជ្រែកដែលមិនសមស្រប ឬគ្មានយុត្តិកម្មណាមួយ ទៅក្នុងកិច្ចការរបស់តុលាការឡើយ ហើយសេចក្តីសំរេចរបស់តុលាការ មិនត្រូវឱ្យមានការពិនិត្យសើរើឡើងវិញដែរ ។ ប៉ុន្តែគោលការណ៍នេះ មិនបានធ្វើអោយប៉ះពាល់ដល់ការពិនិត្យសើរើតាមបែបតុលាការ ឬការបន្ធូរបន្ថយទោស ឬការសំរាលទោសដោយអាជ្ញាធរមានសមត្ថកិច្ចចំពោះការផ្តន្ទាទោសដែលតុលាការបានសំរេចស្របតាមច្បាប់ឡើយ ។

៥- ជនគ្រប់រូប មានសិទ្ធិទទួលបានការជំនុំជំរះទោសពីតុលា-ការធម្មតា ឬសាលាក្តីដែលប្រើប្រាស់នីតិវិធីច្បាប់ដែលមានស្រាប់ ។ សាលាក្តីទាំងឡាយណា ដែលមិនប្រើនីតិវិធីនៃដំណើរការក្តីតាមផ្លូវច្បាប់ដែលមានស្រាប់អោយបានត្រឹមត្រូវទេនោះ សាលាក្តីនោះ មិនត្រូវបង្កើតឡើងដើម្បីជំនួសយុត្តាធិការនៃតុលាការធម្មតា ឬសាលាជំរះក្តីផ្សេងទៀតឡើយ ។

៦- គោលការណ៍ឯករាជ្យភាពរបស់តុលាការ ផ្តល់អំណាច និងតម្រូវឱ្យតុលាការធានាថា ចំណាត់ការតាមផ្លូវច្បាប់ ត្រូវតែប្រព្រឹត្តទៅអោយបានត្រឹមត្រូវ ហើយត្រូវគោរពដល់សិទ្ធិរបស់គូភាគី ។

៧- រដ្ឋសមាជិកនីមួយៗ មានកាតព្វកិច្ចផ្តល់ធនធានអោយបាន

គ្រប់គ្រាន់ដើម្បីឱ្យតុលាការអាចបំពេញមុខងាររបស់ខ្លួនបានត្រឹមត្រូវ

## សេរីភាពក្នុងការបញ្ចេញមតិ និងការបង្កើតសមាគម

៨- អនុលោមតាម សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មន្ត្រីតុលាការក៏ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ មានសិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ ជំនឿ ការបង្កើតសមាគម និងការប្រមូលផ្តុំ។ ប៉ុន្តែក្នុងការប្រើប្រាស់សិទ្ធិទាំងនេះ ចៅក្រម ត្រូវតែប្រកាន់ខ្ជាប់ជានិច្ចនូវឥរិយាបថបែបនេះដើម្បីរក្សាសេចក្តីថ្លៃថ្នូររបស់តុលាការ និងអនាគតិរបស់ខ្លួន ព្រមទាំងរក្សាបានឯករាជ្យភាពរបស់តុលាការ ។

៩- ចៅក្រមទាំងឡាយ ត្រូវមានសិទ្ធិសេរីភាពបង្កើត និងចូលរួមសមាគមចៅក្រម ឬអង្គការដទៃទៀត ដើម្បីតំណាងឱ្យផលប្រយោជន៍របស់ខ្លួន ដើម្បីលើកស្ទួយការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួន និងដើម្បីការពារឯករាជ្យភាពតុលាការ ។

## លក្ខណៈសម្បត្តិ ការជ្រើសរើស និងការបណ្តុះបណ្តាល

១០- បុគ្គលដែលត្រូវជ្រើសរើសឱ្យចូលបំរើការក្នុងតុលាការត្រូវតែជាបុគ្គលសុចរិតទៀងត្រង់ និងមានសមត្ថភាព ដោយមានការ

បណ្តុះបណ្តាលត្រឹមត្រូវ ឬមានលក្ខណៈសម្បត្តិខាងផ្នែកច្បាប់ ។ ការជ្រើសរើសចៅក្រម ទោះបីតាមវិធីណាក៏ដោយ ក៏ត្រូវតែការពារឱ្យផុតពីតាមការចាត់តាំងចៅក្រម ដោយមូលហេតុមិនសមរម្យ ។ ក្នុងការជ្រើសរើសចៅក្រម មិនត្រូវឱ្យមានការរើសអើងចំពោះបុគ្គលណាម្នាក់ ដោយមូលហេតុពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិឬសង្គម ទ្រព្យសម្បត្តិប្រភពកំណើត ឬឋានៈដទៃទៀត លើកលែងតែមានការតម្រូវឱ្យបេក្ខជនសំរាប់តុលាការនោះ ត្រូវតែមានសញ្ជាតិ នៃប្រទេសសាមីនោះប៉ុណ្ណោះ ដែលមិនត្រូវចាត់ទុកថាជាការរើសអើងឡើយ ។

## លក្ខខណ្ឌការងារ និងមុខតំណែង

១១- អាណត្តិការងាររបស់ចៅក្រម ឯករាជ្យភាពរបស់គេ សន្តិសុខ ប្រាក់បៀវត្សរ៍គ្រប់គ្រាន់ លក្ខខណ្ឌការងារ ប្រាក់សោធននិវត្តន៍ និងអាយុចូលនិវត្តន៍របស់ចៅក្រម ត្រូវតែធានាឱ្យបានគ្រប់គ្រាន់ដោយច្បាប់ ។

១២- ចៅក្រមគ្រប់រូប ទោះជាត្រូវតែងតាំងឬត្រូវបោះឆ្នោតជ្រើសរើសក្តី ត្រូវបានធានាអោយកាន់មុខតំណែងរហូតដល់អាយុចូលនិវត្តន៍តាមច្បាប់កំណត់ ឬរហូតដល់ចប់អាណត្តិនៃសាលាក្តីនោះ បើសិនជាសាលាក្តីនោះអាចកើតមានឡើង ។

១៣- ប្រសិនជាមានការតំលើងឋានន្តរសក្តិដល់ចៅក្រម គួរផ្អែកលើកត្តាសត្យានុម័ត ជាពិសេស សមត្ថភាព ភាពសុចរិតទៀងត្រង់ និងបទពិសោធន៍។

១៤- ការបែងចែករឿងក្តីឱ្យដល់ចៅក្រមនៅតាមតុលាការគឺជាកិច្ចការផ្ទៃក្នុងរបស់រដ្ឋបាលតុលាការ។

## ការសំងាត់ខាងវិជ្ជាជីវៈ និងអភ័យឯកសិទ្ធិ

១៥- តុលាការត្រូវមានកាតព្វកិច្ចរក្សាការសំងាត់ខាងវិជ្ជាជីវៈចំពោះការពិភាក្សា និងព័ត៌មានសំងាត់ ដែលទទួលបាននៅក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន ក្រៅតែពីចំណាត់ការទាំងឡាយដែលត្រូវធ្វើជាសាធារណៈ ហើយមិនត្រូវបង្ខំឱ្យតុលាការ បំភ្លឺពីបញ្ហាអាថិកំបាំងទាំងនោះឡើយ។

១៦- ដោយមិនធ្វើឱ្យប៉ះពាល់ដល់នីតិវិធីខាងបទវិន័យណាមួយ ឬដល់សិទ្ធិប្តឹងឧទ្ធរណ៍ ឬការទាមទារសំណងពីរដ្ឋទេ អនុលោមតាមច្បាប់ជាតិ ចៅក្រមគួរតែមានអភ័យឯកសិទ្ធិផ្ទាល់ខ្លួន រួចផុតពីបណ្តឹងរដ្ឋប្បវេណី ចំពោះការទាមទារការខូចខាតជាលុយកាក់ ដោយសារទង្វើមិនត្រឹមត្រូវ ឬការខកខានមិនបានបំពេញមុខងាររបស់ខ្លួនជាចៅក្រម។

## ការដាក់វិន័យ ការព្យួរការងារ និងការដកចេញពីមុខតំណែង

១៧- ការចោទប្រកាន់ ឬបណ្ដឹងតវ៉ាទៅលើចៅក្រមណាមួយ ដែលកំពុងស្ថិតក្នុងមុខតំណែង និងកំពុងប្រកបវិជ្ជាជីវៈ ត្រូវតែចាត់ការដោះស្រាយឱ្យបានរួសរាន់ និងដោយយុត្តិធម៌ តាមនីតិវិធីដ៏ត្រឹមត្រូវមួយ។ ចៅក្រម ត្រូវមានសិទ្ធិទទួលបានការជំនុំជំរះដ៏ត្រឹមត្រូវមួយ។ ការសួរដេញដោលលើរឿងក្ដីក្នុងដំណាក់កាលដំបូង ត្រូវរក្សាទុកជាការសំងាត់ វាលែងតែមានការស្នើសុំពីចៅក្រមរូបនេះ។

១៨- គេអាចព្យួរ ឬដកចៅក្រមចេញពីមុខតំណែងបាន តែដោយសារមូលហេតុអសមត្ថភាព ឬអត្តចរិតមិនសក្តិសមសំរាប់ការបំពេញភារកិច្ចរបស់ខ្លួនជាចៅក្រមតែប៉ុណ្ណោះ។

១៩- រាល់ចំណាត់ការដាក់វិន័យ ការព្យួរ ឬការដកចេញពីមុខតំណែង ត្រូវកំណត់ឱ្យស្របទៅតាមបទដ្ឋាន នៃក្រមសីលធម៌ចៅក្រមដែលមានស្រាប់។

២០- សេចក្ដីសំរេចក្នុងចំណាត់ការដាក់វិន័យ ការព្យួរ ឬការដកចៅក្រមចេញពីមុខតំណែង ត្រូវស្ថិតក្រោមការពិនិត្យមើលឡើងវិញ ដោយឯករាជ្យមួយ។ គោលការណ៍នេះ មិនអាចអនុវត្តចំពោះសេចក្ដីសំរេចរបស់តុលាការជាន់ខ្ពស់ និងសេចក្ដីសំរេចរបស់ស្ថាប័ននីតិបញ្ញត្តិ ក្នុងការចោទប្រកាន់ ឬចំណាត់ការផ្សេងៗទៀត ដែលស្រដៀងគ្នានេះទេ។

# គោលការណ៍ណែនាំ
# ស្ដីពីតួនាទីរបស់ព្រះរាជអាជ្ញា

*អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្ដីពីការបង្ការបទឧក្រិដ្ឋ និងការប្រព្រឹត្តលើជនល្មើស នាទីក្រុងឡាហាវ៉ាន នៃប្រទេសគុយបា ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០ ។*

*ដោយហេតុថា* នៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ប្រជាពលរដ្ឋគ្រប់ជាតិសាសន៍នៅលើពិភពលោក អះអាងពីការប្ដេជ្ញាចិត្តរបស់ខ្លួន ដើម្បីបង្កើតនូវលក្ខខណ្ឌ ដែលអាចរក្សាបានយុត្តិធម៌ ហើយប្រកាសថា ជាគោលបំណងមួយក្នុងចំណោមគោលបំណងទាំងឡាយរបស់ខ្លួន អំពីសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការលើកស្ទួយ និងលើកទឹកចិត្តដល់ការគោរពសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ដោយឥតមានការបែងចែកពូជសាសន៍ ភេទ ភាសា ឬសាសនាឡើយ ។

*ដោយហេតុថា* សេចក្ដីប្រកាសជាសកល ស្ដីពី សិទ្ធិមនុស្ស តំកល់ទុកនូវគោលការណ៍សមភាពចំពោះមុខច្បាប់ ការសន្មត់ជាមុនថាគ្មានទោស និងសិទ្ធិទទួលបានការជំនុំជំរះក្ដីដ៏ត្រឹមត្រូវ និងជាសាធារណៈមួយ ដោយតុលាការមួយ ឯករាជ្យ និងមិនលំអៀង ។

*ដោយហេតុថា* ជាញឹកញាប់ នៅមានចន្លោះមួយរវាងទស្សនៈជាគន្លឹះដែលនៅពីក្រោយគោលការណ៍ទាំងនេះ និងស្ថានការណ៍ពិត ។

*ដោយហេតុថា* ការរៀបចំ និងការគ្រប់គ្រងយុត្តិធម៌ នៅតាមបណ្តាប្រទេសនានា ត្រូវតែធ្វើតាមគោលការណ៍ទាំងនេះ ហើយត្រូវខិតខំប្រឹងប្រែងធ្វើការបកស្រាយគោលការណ៍ទាំងនេះ ឱ្យក្លាយជាការពិតយ៉ាងពេញលេញ ។

*ដោយហេតុថា* ព្រះរាជអាជ្ញាមានតួនាទីដ៏សំខាន់ ក្នុងការគ្រប់គ្រងយុត្តិធម៌ និងវិធានទាំងឡាយ ដែលទាក់ទងដល់ការបំពេញការទទួលខុសត្រូវដ៏សំខាន់របស់ខ្លួន គួរតែលើកស្ទួយការគោរព និងការប្រតិបត្តិរបស់ខ្លួន តាមគោលការណ៍ទាំងឡាយ ដែលបានពោលខាងលើ ដែលជាការរួមចំណែកដល់យុត្តិធម៌ព្រហ្មទណ្ឌដ៏ត្រឹមត្រូវ និងសមភាព ហើយក៏រួមចំណែកដល់ការការពារដ៏មានប្រសិទ្ធភាព ដល់ប្រជាពលរដ្ឋពីឧក្រិដ្ឋកម្ម ។

*ដោយហេតុថា* នេះជាការចាំបាច់ត្រូវធានាថា ព្រះរាជអាជ្ញាមានលក្ខណៈសម្បត្តិវិជ្ជាជីវៈតាមការទាមទារ ក្នុងការបំពេញមុខងាររបស់ខ្លួន តាមវិធីដ៏ប្រពៃនៃការជ្រើសរើសនិងការហ្វឹកហ្វឺនផ្នែកច្បាប់និងវិជ្ជាជីវៈ និងតាមរយៈការផ្តល់នូវគ្រប់មធ្យោបាយចាំបាច់ ដើម្បីបំពេញតួនាទីរបស់ខ្លួនអោយបានត្រឹមត្រូវ ក្នុងការប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋ ជាពិសេសវិសាលភាព និងទំរង់ថ្មីៗនៃបទឧក្រិដ្ឋទាំងនោះ។

*ដោយហេតុថា* តាមសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ៣៤/១៦៩ ចុះថ្ងៃទី១៧-ធ្នូ-១៩៧៩ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់ តាមអនុសាសន៍របស់សមាជសហប្រជាជាតិលើកទី៥ ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់

គ្រងជនល្មើស ។

*ដោយហេតុថា* នៅក្នុងសេចក្តីសំរេចចិត្តលេខ១៦ នៃសមាជសហប្រជាជាតិលើកទី៥ ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស គណៈកម្មាធិការគ្រប់គ្រង និងបង្ការបទឧក្រិដ្ឋ ត្រូវបានស្នើសុំអោយដាក់បញ្ចូលទៅក្នុងចង្កោមអាទិភាពរបស់ខ្លួន នូវការតាក់តែងគោលការណ៍ណែនាំទាំងឡាយ ដែលទាក់ទងនឹងឯករាជ្យភាពរបស់ចៅក្រម ព្រមទាំងការជ្រើសរើស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឋានៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ។

*ដោយហេតុថា* សមាជសហប្រជាជាតិលើកទី៧ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស បានអនុម័តគោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាព នៃតុលាការ ហើយត្រូវបានគាំកល់ជាបន្តបន្ទាប់មកទៀត ដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ៤០/៣២ ចុះថ្ងៃទី២៩-១១-១៩៨៥ និងសេចក្តីសំរេចចិត្តលេខ៤០/១៤៦ ចុះថ្ងៃទី១៣-១២-១៩៨៥ ។

*ដោយហេតុថា* សេចក្តីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សំរាប់ជនរងគ្រោះពីបទឧក្រិដ្ឋ និងការរំលោភអំណាច ផ្តល់អនុសាសន៍អោយចាត់វិធានការនានានៅថ្នាក់ជាតិ និងអន្តរជាតិដើម្បីកែលំអពីសិទ្ធិទទួលបានយុត្តិធម៌ និងការប្រព្រឹត្តដ៏ត្រឹមត្រូវ បដិទានការសងសំណង និងការជួយសង្គ្រោះដល់ជនរងគ្រោះនៃបទឧក្រិដ្ឋ ។

*ដោយហេតុថា* នៅក្នុងសេចក្តីសំរេចចិត្តលេខ៧របស់សមាជលើកទី៧ គណៈកម្មាធិការគ្រប់គ្រង និងបង្ការបទឧក្រិដ្ឋ ត្រូវបាន

ស្នើសុំអោយពិចារណាពីសេចក្តីត្រូវការ ចំពោះគោលការណ៍ណែនាំ ដែលទាក់ទងនឹង ដូចជាការជ្រើសរើស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឋានៈរបស់ព្រះរាជអាជ្ញា ក្រមសីលធម៌ និងតួនាទីដែលគេរំពឹងមធ្យោបាយនានា ដើម្បីលើកកំពស់ការរួមវិភាគទានរបស់គេ ក្នុងដំណើការអោយកាន់តែរលូន នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងកិច្ចសហប្រតិបត្តិការរបស់គេជាមួយនគរបាល ទំហំនៃអំណាចឆន្ទានុសិទ្ធិ និងតួនាទីរបស់គេក្នុងចំណាត់ការព្រហ្មទណ្ឌ ព្រមទាំងចូលរួមក្នុងការធ្វើរបាយការណ៍ជូនបណ្តាសមាជសហប្រជាជាតិនាពេលអនាគត ។

គោលការណ៍ណែនាំដូចមានចែងខាងក្រោមនេះដែលត្រូវបានតាក់តែងឡើង ដើម្បីជួយដល់រដ្ឋសមាជិក ក្នុងការងាររបស់ខ្លួន ដើម្បីធានា និងលើកស្ទួយប្រសិទ្ធភាព ភាពមិនលំអៀង និងភាពត្រឹមត្រូវរបស់ព្រះរាជអាជ្ញា នៅក្នុងចំណាត់ការរឿងព្រហ្មទ័ណ្ឌ គប្បីត្រូវបានគោរពតាម និងយកទៅពិចារណាដោយរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនៃនីតិកម្មជាតិ និងការអនុវត្តន៍ជាក់ស្តែងរបស់ខ្លួន ហើយគួរតែត្រូវទាញការចាប់អារម្មណ៍របស់ព្រះរាជអាជ្ញា ព្រមទាំងអ្នកដទៃទៀត ដូចជាចៅក្រម មេធាវី សមាជិកនៃអង្គនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ និងសាធារណៈជនជាទូទៅ ។ គោលការណ៍ណែនាំនេះ ត្រូវបានតាក់តែងឡើងជាសំខាន់សំរាប់ព្រះរាជអាជ្ញា ក៏ប៉ុន្តែគោលការណ៏ទាំងនេះ ក៏អនុវត្តបានដោយស្មើភាពគ្នា ចំពោះព្រះរាជអាជ្ញាទាំងឡាយ ដែលត្រូវបានតែងតាំងឡើង ដោយឈរលើមូលដ្ឋានចំពោះមុខ តាមការសមស្រប ។

## លក្ខណៈសម្បត្តិ ការជ្រើសរើស និងការបណ្តុះបណ្តាល

១- ជនទាំងឡាយដែលត្រូវបានជ្រើសរើសធ្វើជាព្រះរាជអាជ្ញា ត្រូវតែជាឯកត្តជនដែលមានសេចក្តីសុចរិត និងមានសមត្ថភាព ព្រមទាំងមានការបណ្តុះបណ្តាល និងមានលក្ខណៈសម្បត្តិសមរម្យផង។

២- រដ្ឋទាំងឡាយ ត្រូវធានាថា ៈ

(ក) លក្ខណៈជ្រើសរើសព្រះរាជអាជ្ញា ត្រូវមានការការពារមិនឱ្យមានការតែងតាំងទាំងឡាយណាដែលឈរលើភាពលំអៀង ឬបុរេវិនិច្ឆ័យ ដោយបំបាត់ចោលនូវការរើសអើងណាមួយ ចំពោះបុគ្គលដោយមកពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ សង្គម ឬដើមកំណើត ជាតិពន្ធុ ទ្រព្យសម្បត្តិ ប្រភពកំណើត ឋានៈសេដ្ឋកិច្ច ឬឋានៈដទៃទៀត លើកលែងតែការតំរូវឱ្យបេក្ខជនសំរាប់ការិយាល័យអយ្យការនោះ ត្រូវតែមានសញ្ជាតិនៃប្រទេសសាមីប៉ុណ្ណោះ ដែលមិនត្រូវបានចាត់ទុកថាជាការរើសអើង។

(ខ) ព្រះរាជអាជ្ញា ត្រូវមានការអប់រំ និងការបណ្តុះបណ្តាលសមស្រប ហើយត្រូវឱ្យយល់ដឹងអំពីឧត្តមគតិ និងករណីយកិច្ចប្រកបដោយសីលធម៌នៃតួនាទីរបស់ខ្លួន យល់ដឹងអំពីការការពាររដ្ឋធម្មនុញ្ញ និងច្បាប់សំរាប់សិទ្ធិរបស់ជនជាប់សង្ស័យ និងជនរងគ្រោះ ហើយក៏ត្រូវយល់ដឹងអំពីសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្តដែលទទួលស្គាល់ដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិផង។

## ឋានៈ និងលក្ខខណ្ឌនៃសេវាកម្ម

៣- ក្នុងនាមជាភ្នាក់ងារដ៏សំខាន់ ក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវរក្សាខ្ជាប់គ្រប់ពេលវេលា នូវកិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈរបស់ខ្លួន។

៤- រដ្ឋត្រូវធានាថា ព្រះរាជអាជ្ញាមានលទ្ធភាពអាចបំពេញមុខងារតាមវិជ្ជាជីវៈរបស់ខ្លួន ដោយគ្មានការបំភិតបំភ័យ ការបង្អាក់ ការយាយីរំខាន ការជ្រៀតជ្រែកមិនសមស្រប ឬដាក់ឱ្យទទួលខុសត្រូវខាងរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬការទទួលខុសត្រូវដទៃទៀតដោយមិនសមហេតុផល។

៥- ព្រះរាជអាជ្ញា និងក្រុមគ្រួសាររបស់គេ ត្រូវតែមានកិច្ចការពារខាងផ្លូវកាយពីសំណាក់អាជ្ញាធរ នៅពេលណាដែលសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ ទទួលនូវការគំរាមកំហែង ដោយសារតែការបំពេញមុខងារជាព្រះរាជអាជ្ញានោះទេ។

៦-ការកំណត់លក្ខខណ្ឌសេវាកម្មដ៏សមហេតុផលរបស់ព្រះរាជអាជ្ញា ប្រាក់បៀវត្សរ៍គ្រប់គ្រាន់សំរាប់ការងារ និងនៅពេលណាដែលអាចអនុវត្តបាន រយៈពេលកាន់មុខតំណែង ប្រាក់សោធននិវត្តន៍ និងអាយុចូលនិវត្តន៍ ត្រូវតែមានចែងក្នុងច្បាប់ ឬវិធាន ឬបទបញ្ជាទាំងឡាយដែលបានចេញផ្សាយ។

៧- ការតម្លើងឋានៈព្រះរាជអាជ្ញានៅទីណាក៏ដោយដែលមានប្រព័ន្ធបែបនេះ ត្រូវផ្អែកលើកត្តាសន្យានុម័តនានា ជាពិសេស គឺ

លក្ខណៈសម្បត្តិខាងវិជ្ជាជីវៈ សមត្ថភាព សេចក្តីសុចរិត និងបទពិសោធន៍ ហើយត្រូវសំរេចឱ្យបាន ស្របតាមនីតិវិធីត្រឹមត្រូវ និងមិនលំអៀង។

## *សេរីភាពក្នុងការបញ្ចេញមតិ និងការបង្កើតសមាគម*

៨- ព្រះរាជអាជ្ញាក៏ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ គឺមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ជំនឿ ការបង្កើតសមាគម និងការប្រជុំ។ ជាពិសេស ព្រះរាជអាជ្ញា មានសិទ្ធិចូលរួមចំណែកក្នុងការពិភាក្សាជាសាធារណៈ នូវរាល់បញ្ហាដែលទាក់ទងនឹងច្បាប់ ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ និងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ព្រមទាំងចូលរួម ឬបង្កើតអង្គការប្រចាំមូលដ្ឋាន អង្គការជាតិ ឬអន្តរជាតិ និងចូលរួមការប្រជុំរបស់អង្គការទាំងនេះ ដោយគ្មានការទទួលរង នូវការបាត់បង់ផលប្រយោជន៍ខាងវិជ្ជាជីវៈ ដោយសារតែមូលហេតុនៃសកម្មភាពស្របច្បាប់ ឬដោយសារសមាជិកភាពរបស់គេនៅក្នុងអង្គការស្របច្បាប់ណាមួយនោះឡើយ។ ក្នុងការប្រើប្រាស់សិទ្ធិទាំងអស់នេះ ព្រះរាជអាជ្ញាត្រូវតែប្រតិបត្តិខ្លួនឱ្យស្របតាមច្បាប់ និងបទដ្ឋាន ព្រមទាំងបញ្ញត្តិក្រមសីលធម៌ទាំងឡាយនៃវិជ្ជាជីវៈរបស់ខ្លួន ដែលត្រូវបានទទួលស្គាល់ជានិច្ច។

៩- ព្រះរាជអាជ្ញា ត្រូវមានសិទ្ធិសេរីភាពចូលរួម និងបង្កើតសមាគមវិជ្ជាជីវៈ ឬអង្គការដទៃទៀតដើម្បីតំណាងឱ្យផលប្រយោជន៍របស់ខ្លួន ដើម្បីលើកស្ទួយការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួន និង

ដើម្បីការពារឋានៈរបស់ខ្លួន ។

## *តួនាទីព្រះរាជអាជ្ញាក្នុងចំណាត់ការរឿងក្តីព្រហ្មទណ្ឌ*

១០- មុខងារអយ្យការ ត្រូវតែចែកឱ្យដាច់ស្រលះពីមុខងារចៅក្រម ។

១១- ព្រះរាជអាជ្ញា ត្រូវបំពេញតួនាទីយ៉ាងសកម្មមួយ ក្នុងចំណាត់ការរឿងក្តីព្រហ្មទណ្ឌ រួមទាំងស្ថាប័នអយ្យការ ហើយដែលច្បាប់អនុញ្ញាតិ ឬស្របតាមការអនុវត្តន៏ក្នុងស្រុកក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលនីត្យានុកូលភាពនៃការស៊ើបអង្កេត ពិនិត្យមើលការអនុវត្តន៏សេចក្តីសំរេចរបស់តុលាការ និងការបំពេញតួនាទីផ្សេងៗទៀត ដោយតំណាងឱ្យផលប្រយោជន៏សាធារណៈ ។

១២- អនុលោមតាមច្បាប់ ព្រះរាជអាជ្ញា ត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ និងឱ្យបានឆាប់រហ័ស ហើយត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលើកកំពស់សិទ្ធិមនុស្ស ហេតុដូច្នេះ ត្រូវរួមចំណែកក្នុងការធានាដល់កិច្ចដំណើរការដ៏ត្រឹមត្រូវ និងការប្រព្រឹត្តិទៅអោយបានរលូន នៃប្រព័ន្ធយុត្តិធមិព្រហ្មទណ្ឌ ។

១៣- ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ :

(ក) អនុវត្តមុខងាររបស់ខ្លួន ដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទ វប្បធមិ ជាតិសាសន៏ សាសនា សង្គម

នយោបាយ ឬការរើសអើងណាមួយផ្សេងទៀត ។

(ខ) ការពារផលប្រយោជន៍សាធារណៈ អំពើជាសត្យានុម័ត យកចិត្តទុកដាក់អោយបានល្អចំពោះជនសង្ស័យ និងជនរងគ្រោះ និងត្រូវយកចិត្តទុកដាក់ចំពោះគ្រប់កាលៈទេសៈដែលពាក់ព័ន្ធ ដោយមិនគិតថា កាលៈទេសៈនោះ មានប្រយោជន៍ ឬឥតមានប្រយោជន៍ដល់ជនសង្ស័យក៏ដោយ ។

(គ) រក្សារឿងក្ដីជាការសម្ងាត់ បើពុំដូច្នេះទេ លុះត្រាតែការបំពេញភារកិច្ច ឬសេចក្ដីត្រូវការយុត្តិធមិតំរូវ ។

(ឃ) ពិនិត្យមើលពីទិដ្ឋភាព និងក្ដីបារម្ភរបស់ជនរងគ្រោះ នៅពេលដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់របស់ពួកគេ និងធានាថា ជនរងគ្រោះត្រូវបានប្រាប់ពីសិទ្ធិរបស់ពួកគេ អនុលោមតាមសេចក្ដីប្រកាសពីគោលការណ៍ជាមូលដ្ឋាន នៃយុត្តិធមិ សំរាប់ជនរងគ្រោះពីបទឧក្រិដ្ឋ និងការរំលោភអំណាច ។

១៤- ព្រះរាជអាជ្ញាមិនត្រូវផ្ដើមគំនិត ឬបន្តការចោទប្រកាន់ ឬក៏ត្រូវខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីពំកល់រឿងទុកឥតចាត់ការ ប្រសិនបើ ការស៊ើបអង្កេតដោយឥតលំអៀងមួយ បង្ហាញឱ្យឃើញថា ការចោទប្រកាន់នេះ ពុំមានមូលដ្ឋានទេនោះ ។

១៥- ព្រះរាជអាជ្ញា ត្រូវផ្ដល់ការយកចិត្តទុកដាក់អោយបានម៉ត់ចត់ ចំពោះការធ្វើបណ្ដឹងអាជ្ញានៃបទល្មើស ដែលប្រព្រឹត្តិដោយមន្ត្រីសាធារណៈ ជាពិសេសអំពើពុករលួយ ការរំលោភអំណាច ការ

រំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋដទៃទៀតដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយដែលអនុញ្ញាតដោយច្បាប់ ឬស្របតាមការអនុវត្តន៍ក្នុងស្រុក ពីការស៊ើបអង្កេតអំពីបទល្មើសទាំងនេះ ។

១៦- នៅពេលដែលព្រះរាជអាជ្ញា ទទួលបានភស្តុតាងប្រឆាំងចំពោះជនជាប់សង្ស័យដែលលោកដឹង ឬជឿជាក់ លើមូលដ្ឋានសមហេតុផលថា ភស្តុតាងទាំងនោះ បានមកដោយប្រើវិធីមិនស្របច្បាប់ដែលបង្កើតជាការរំលោភយ៉ាងធ្ងន់ធ្ងរ លើសិទ្ធិមនុស្សរបស់ជនជាប់សង្ស័យ ជាពិសេសទាក់ទងទៅនឹងការធ្វើទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តិកម្ម ដ៏ឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប ឬការរំលោភសិទ្ធិមនុស្សផ្សេងៗទៀតនោះ ព្រះរាជអាជ្ញាត្រូវបដិសេធមិនប្រើភស្តុតាងបែបនេះ ប្រឆាំងនឹងជនណាម្នាក់ឡើយ ក្រៅពីអ្នកដែលបានប្រើវិធីបែបនោះខ្លួនឯង ឬត្រូវជំរាបដល់តុលាការតាមនោះ ហើយត្រូវចាត់គ្រប់វិធានការចាំបាច់ដើម្បីធានាថាអ្នកដែលទទួលខុសត្រូវចំពោះការប្រើវិធីបែបនេះ ត្រូវបាននាំខ្លួនមកកាន់តុលាការ ។

## *មុខការឆន្ទានុសិទ្ធ*

១៧- នៅបណ្ដាប្រទេសដែលព្រះរាជអាជ្ញាត្រូវបានប្រគល់ឱ្យនូវមុខការឆន្ទានុសិទ្ធិ ច្បាប់ ឬវិធាននិងបទបញ្ជាទាំងឡាយដែលបានចេញផ្សព្វផ្សាយ ត្រូវមានចែងអំពីគោលការណ៍ណែនាំ ដើម្បីលើកកំពស់ភាពត្រឹមត្រូវ និងភាពមិនប្រែប្រួលនៃវិធីធ្វើសេចក្ដីសំរេចនានា

ក្នុងដំណើរការធ្វើបណ្តឹងអាជ្ញា ដោយរួមទាំងការបង្កើត ឬការលប់ចោលបណ្តឹងអាជ្ញាផង ។

## *ជំរើសផ្សេងៗក្នុងការធ្វើបណ្តឹងអាជ្ញា*

១៨- អនុលោមតាមច្បាប់ជាតិ ព្រះរាជអាជ្ញាត្រូវធ្វើការពិចារណាអោយបានសមស្រប ក្នុងការលប់ចោលបណ្តឹងអាជ្ញា បញ្ឈប់ចំណាត់ការរឿងក្តីដោយមានល័ក្ខខ័ណ្ឌ ឬឥតល័ក្ខខ័ណ្ឌ ឬដោយការបង្វែររឿងព្រហ្មទ័ណ្ឌ ចេញពីប្រព័ន្ធយុត្តិធម៌ជាផ្លូវការ ដោយគោរពយ៉ាងពេញលេញដល់សិទ្ធិរបស់ជនជាប់សង្ស័យ និងជនរងគ្រោះ ។ តាមគោលបំណងនេះ រដ្ឋទាំងឡាយ ត្រូវរិះរកគ្រប់លទ្ធភាពក្នុងការអនុម័តយក តាមគំរោងការបង្វែរ ដែលមិនត្រឹមតែជួយសំរាលបន្ទុករបស់តុលាការដ៏ច្រើនលើសលប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយជៀសវាងបានពីស្លាកស្នាមទុយសិ នៃការឃុំខ្លួនមុនការជំនុំជំរះក្តី កាចោទប្រកាន់ និងការផ្តន្ទាទោស ព្រមទាំងពីផលមិនល្អ ដែលអាចកើតមានពីការដាក់ឱ្យជាប់ពន្ធនាគារទៀតផង ។

១៩- នៅបណ្តាប្រទេសដែលព្រះរាជអាជ្ញាត្រូវបានផ្តល់ឱ្យនូវមុខការឆន្ទានុសិទ្ធិ ដូចជា ការសំរេចថាតើត្រូវធ្វើបណ្តឹងអាជ្ញាចំពោះអនីតិជនម្នាក់ ឬអត់នោះ ព្រះរាជអាជ្ញាត្រូវតែផ្តោតការពិចារណាជាពិសេសទៅលើចរិក និងភាពធ្ងន់ធ្ងរនៃបទល្មើស កិច្ចការពារពីសង្គម

និងបុគ្គលិកលក្ខណៈ និងសាវតា របស់អនីតិជននោះសិន។ ក្នុងការធ្វើសេចក្តីសំរេចនោះ ព្រះរាជអាជ្ញា ត្រូវពិចារណាជាពិសេស អំពីជំរើសផ្សេងៗដែលអាចមាន ដើម្បីជំនួសឱ្យការធ្វើបណ្តឹងអាជ្ញាតាមច្បាប់ និងនីតិវិធីទាំងឡាយ ដែលពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន។ ព្រះរាជអាជ្ញា ត្រូវព្យាយាមខិតខំឱ្យអស់ពីលទ្ធភាពរបស់ខ្លួន ក្នុងការចាត់វិធានការធ្វើបណ្តឹងអាជ្ញាចំពោះអនីតិជន តែនៅពេលណាដែលចាំបាច់ជាអប្បបរិមាប៉ុណ្ណោះ។

## ***ទំនាក់ទំនងជាមួយក្រសួងឬស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល***

២០- ដើម្បីធានាពីភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃការធ្វើបណ្តឹងអាជ្ញា ព្រះរាជអាជ្ញា ត្រូវខិតខំឱ្យអស់ពីសមត្ថភាព សហការជាមួយនគរបាល តុលាការ មេធាវី ស្ថាប័នសាធារណៈ និងជាមួយក្រសួង ឬស្ថាប័នផ្សេងៗទៀតរបស់រដ្ឋាភិបាល។

## ***ដំណើរការដាក់ទណ្ឌកម្មផ្នែកវិន័យ***

២១- អំពើល្មើសវិន័យរបស់ព្រះរាជអាជ្ញា ត្រូវផ្អែកទៅលើច្បាប់ ឬបទបញ្ញាស្របច្បាប់នានា។ បណ្តឹងប្រឆាំងនឹងព្រះរាជអាជ្ញាដោយចោទប្រកាន់ថា ព្រះរាជអាជ្ញានោះបានប្រព្រឹត្តិយ៉ាងប្រត្យក្សនូវអំពើដែលប្រាសចាកពីបទដ្ឋានវិជ្ជាជីវៈ ត្រូវចាត់ការដោះស្រាយឱ្យបានឆាប់រហ័ស និងត្រឹមត្រូវតាមនីតិវិធីសមស្រប។ ព្រះរាជអាជ្ញា

មានសិទ្ធិទទួលបាននូវសវនាការដ៏ត្រឹមត្រូវមួយ ។ សេចក្តីសំរេច ត្រូវស្ថិតនៅក្រោមការពិនិត្យមើលឡើងវិញដោយឯករាជ្យ ។

២២- ចំណាត់ការដាក់វិន័យលើព្រះរាជអាជ្ញា ត្រូវធានាពីការវាយតម្លៃ និងការសំរេចជាសត្យានុម័ត ។ ចំណាត់ការទាំងនេះ ត្រូវតែសំរេចដោយស្របតាមច្បាប់ ស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងបទដ្ឋាន និងបញ្ញត្តិក្រមសីលធម៌ដទៃទៀតដែលបានបង្កើតឡើង ហើយនិងស្របតាមស្មារតីនៃគោលការណ៍ណែនាំនេះ ។

## *ការប្រតិបត្តិគោលការណ៍ណែនាំនេះ*

២៣- ព្រះរាជអាជ្ញាត្រូវគោរពតាមគោលការណ៍ណែនាំនេះ ។ ព្រះរាជអាជ្ញា ក៏ត្រូវបង្ការ និងជំទាស់យ៉ាងសកម្មនឹងការរំលោភណាមួយ ដែលកើតមាន ឱ្យអស់ពីសមត្ថភាពដែលខ្លួនអាចធ្វើទៅបានផងដែរ ។

២៤- ព្រះរាជអាជ្ញាដែលមានហេតុផល ដើម្បីជឿថា ការរំលោភណាមួយ ទៅលើគោលការណ៍ណែនាំនេះ បានកើតឡើង ឬជិតនឹងកើតឡើងនោះ ត្រូវរាយការណ៍ពីបញ្ហានោះដល់អាជ្ញាធរថ្នាក់លើរបស់ខ្លួន ហើយបើសិនជាចាំបាច់ ត្រូវរាយការណ៍ដល់អាជ្ញាធរ ឬអង្គការសមស្របនានា ដែលមានអំណាចដោះស្រាយ ឬពិនិត្យមើលឡើងវិញ ។

# គោលការណ៍ជាមូលដ្ឋាន ស្ដីពីតួនាទីរបស់មេធាវី

*ត្រូវបានអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៨ ស្ដីពីការបង្ការបទល្មើស និងការប្រព្រឹត្តលើជនល្មើសដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងឡាហាវ៉ាន ប្រទេសគុយបា ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០ ហើយត្រូវបានគាំកល់ដោយសេចក្ដីសំរេចចិត្តលេខ៤៨/១៣៧ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ របស់មហាសន្និបាត អ.ស.ប. ។*

*ដោយហេតុថា* នៅក្នុងធម្មនុញ្ញ អង្គការសហប្រជាជាតិ ប្រជាពលរដ្ឋគ្រប់ជាតិសាសន៍នៅលើពិភពលោក អះអាងពីការប្ដេជ្ញាចិត្តរបស់ខ្លួនថា នឹងបង្កើតនូវលក្ខខណ្ឌនានា ដែលអាចរក្សាបាននូវយុត្តិធម៌ និងប្រកាសថា នេះគឺជាផ្នែកមួយនៃបំណងប្រាថ្នារបស់គេចំពោះសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការលើកស្ទួយ និងជំរុញឱ្យមានការគោរពសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត ដោយគ្មានការបែងចែកពូជសាសន៍ ភេទ ភាសា និងសាសនាឡើយ ។

*ដោយហេតុថា* សេចក្ដីថ្លែងការណ៍ជាសាកលស្ដីពីសិទ្ធិមនុស្ស តំកល់ គោលការណ៍សមភាពចំពោះមុខច្បាប់ គោលការណ៍ស្ដីពីការសន្មត់ជាមុនថាគ្មានទោស សិទ្ធិទទួលបាននូវការជំនុំជំរះប្រកបដោយយុត្តិធម៌ និងជាសាធារណៈ ដោយតុលាការមួយ ឯករាជ្យ និងមិន

លំអៀង ព្រមទាំងការធានាទាំងអស់ ដែលចាំបាច់សំរាប់ការការពារ ដល់ជនគ្រប់រូបដែលត្រូវចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។

*ដោយហេតុថា* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយប្រកាសជាបន្ថែមទៀតពីសិទ្ធិទទួលបាននូវការជំនុំជំរះ ដោយគ្មានការពន្យាពេលមិនសមហេតុផល និងសិទ្ធិទទួលបាននូវការ ជំនុំជំរះប្រកបដោយយុត្តិធម៌ និងជាសាធារណៈ ដោយតុលាការមួយ មានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ហើយដែលតុលាការនេះ ត្រូវបានបង្កើតឡើងដោយច្បាប់ ។

*ដោយហេតុថា* កតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រំលឹកពីកាតព្វកិច្ចនៃរដ្ឋជាសមាជិក ក្រោម កតិកាសញ្ញានេះ អោយលើកស្ទួយការគោរពជាសកល និងការប្រតិ បត្តិតាមសិទ្ធិមនុស្ស និងសេរីភាព ។

*ដោយហេតុថា* គោលការណ៍សមូហកម្មសំរាប់ការការពារជន គ្រប់រូប ដែលស្ថិតក្រោមការឃុំឃាំង ឬការដាក់ពន្ធនាគារតាមទំរង់ ណាក៏ដោយ ចែងថា អ្នកជាប់ឃុំឃាំងត្រូវមានសិទ្ធិទទួលបានជំនួយ ព្រមទាំងធ្វើទំនាក់ទំនង និងប្រឹក្សាយោបល់ជាមួយស្នាក្តី ។

*ដោយហេតុថា* បញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រង អ្នកទោស ផ្តល់អនុសាសន៍ជាពិសេសថា ជំនួយផ្នែកច្បាប់ និងទំនាក់

ទំនងជាសំងាត់ជាមួយស្នាក្ដីគួរត្រូវបានធានាចំពោះពិរុទ្ធជនទាំងអស់។

*ដោយហេតុថា* សេចក្ដីថ្លែងការណ៍ស្ដីពីការធានាអោយមានការការពារចំពោះជនទាំងអស់ ដែលប្រឈមមុខនឹងទោសប្រហារជីវិត ធ្វើការគូសបញ្ជាក់ជាថ្មី ពីសិទ្ធិនៃជនរាល់រូបដែលសង្ស័យ ឬដែលត្រូវចោទប្រកាន់ពីបទអាជ្ញា ដែលអាចកាត់ទោសប្រហារជីវិតអោយមានជំនួយផ្នែកច្បាប់គ្រប់គ្រាន់ នៅគ្រប់តំណាក់កាលទាំងអស់នៃនីតិវិធី អនុលោមតាមមាត្រា១៤ នៃកតិកាសញ្ញាស្ដីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។

*ដោយហេតុថា* សេចក្ដីថ្លែងការណ៍ នៃគោលការណ៍ជាមូលដ្ឋាន ស្ដីពីយុត្តិធម៌ សំរាប់ជនរងគ្រោះ នៃបទអាជ្ញា និងការរំលោភអំណាច ផ្ដល់អនុសាសន៍អោយចាត់វិធានការនៅថ្នាក់ជាតិ និងអន្ដរជាតិ ដើម្បីកែលំអពីសិទ្ធិទទួលបានយុត្តិធម៌ និងការប្រព្រឹត្ត បដិទានការទូទាត់សំណង និងការជួយឧបត្ថម្ភដល់ជនរងគ្រោះដោយសារបទអាជ្ញា អោយបានត្រឹមត្រូវវិញ ។

*ដោយហេតុថា* ការការពារគ្រប់គ្រាន់ដល់សិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ដដែលជនគ្រប់រូបសុទ្ធតែមានសិទ្ធិទទួលបានទោះជាសិទ្ធិទាំងនោះជាសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឬជាសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ក៏នៅតែតំរូវអោយជនគ្រប់រូបមានសិទ្ធិទទួលបាននូវសេវាកម្មផ្នែកច្បាប់ដ៏មានប្រសិទ្ធភាព ដែលផ្ដល់ដោយអ្នកប្រកប

វិជ្ជាជីវៈច្បាប់ឯករាជ្យមួយ ។

*ដោយហេតុថា* សមាគមវិជ្ជាជីវៈមេធាវីនានាដើរតួនាទីយ៉ាងសំខាន់ ក្នុងការលើកកំពស់បទដ្ឋានវិជ្ជាជីវៈ និងបញ្ញត្តិក្រមសីលធម៌ ក្នុងការការពារសមាជិករបស់ខ្លួន ពីការចោទប្រកាន់ និងការដាក់កំហិតមិនសមរម្យ និងការរំលោភបំពាន ក្នុងការផ្តល់សេវាកម្មច្បាប់ដល់ជនគ្រប់រូប ដែលត្រូវការមេធាវី ព្រមទាំងក្នុងការសហការជាមួយស្ថាប័នរដ្ឋាភិបាល និងស្ថាប័នដទៃទៀតដើម្បីឆ្ពោះទៅកាន់គោលដៅយុត្តិធម៌ និងផលប្រយោជន៍សាធារណៈ ។

គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវីដូចមានចែងខាងក្រោមនេះ ដែលត្រូវបានបង្កើតឡើង ដើម្បីជួយរដ្ឋជាសមាជិកនានា ក្នុងការបំពេញភារកិច្ចរបស់ខ្លួនសំរាប់ធានា និងលើកស្ទួយនូវតួនាទីដ៏ត្រឹមត្រូវរបស់មេធាវីដែលរដ្ឋាភិបាលទាំងឡាយ គួរយកមកពិចារណា និងគោរពតាមក្នុងក្របខ័ណ្ឌនៃច្បាប់ជាតិរបស់ខ្លួន និងក្នុងការអនុវត្តន៍ជាក់ស្តែង ហើយមេធាវី និងអ្នកដទៃទៀត ដូចជាចៅក្រម ព្រះរាជអាជ្ញា សមាជិកនៃអង្គនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ និងសាធារណៈជនទូទៅ គួរតែយកចិត្តទុកដាក់ចំពោះគោលការណ៍ជាមូលដ្ឋាននេះ។ គោលការណ៍ទាំងនេះក៏ត្រូវអនុវត្តអោយបានសមរម្យផងដែរ ចំពោះជនទាំងឡាយណាដែលប្រើប្រាស់មុខងារជាមេធាវី តែមិនបានចុះបញ្ជីផ្លូវការជាមួយសមាគមមេធាវី ។

## សិទ្ធិទទួលបានមេធាវី និងសេវាកម្មច្បាប់

១- បុគ្គលគ្រប់រូប មានសិទ្ធិពឹងពាក់រកជំនួយពីមេធាវីម្នាក់តាមការជ្រើសរើសរបស់ខ្លួន ដើម្បីការពារ និងបង្កើតសិទ្ធិរបស់ខ្លួន ព្រមទាំងដើម្បីការពារខ្លួន នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើររឿងក្តីព្រហ្មទណ្ឌ។

២- រដ្ឋាភិបាលនានាត្រូវធានាថា បុគ្គលគ្រប់រូបដែលស្ថិតនៅក្រោមដែនដីរបស់ខ្លួន និងស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវទទួលបាននូវនីតិវិធីប្រកបដោយសមត្ថភាព និងយន្តការឆ្លើយតបដ៏មានប្រសិទ្ធភាព ព្រមទាំងសិទ្ធិស្មើគ្នាទទួលបានមេធាវីដោយគ្មានការបែងចែកពីប្រភេទអ្វីទាំងអស់ ដូចជាការរើសអើងពូជសាសន៍ ពណ៌សំបុរ ដើមកំណើត ជាតិពន្ធុ ភេទ ភាសា សាសនា គំនិតនយោបាយ ឬការបញ្ចេញមតិដទៃទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ប្រភពកំណើត ឋានៈសេដ្ឋកិច្ច ឬឋានៈដទៃទៀត។

៣- រដ្ឋាភិបាលនានា ត្រូវធានាអោយមានការផ្តល់មូលនិធិ និងប្រភពដទៃទៀតអោយបានគ្រប់គ្រាន់ សំរាប់សេវាកម្មច្បាប់ដល់ជនក្រីក្រ និងតាមការចាំបាច់ ដល់ជនដទៃទៀតដែលងាយរងគ្រោះ។ សមាគមវិជ្ជាជីវៈមេធាវីនានាត្រូវសហការក្នុងការរៀបចំ និងការផ្តល់សេវាកម្ម មធ្យោបាយ និងប្រភពដទៃទៀតទាំងនេះ។

៤- រដ្ឋាភិបាល និងសមាគមវិជ្ជាជីវៈមេធាវីនានា ត្រូវធ្វើការផ្សព្វ-ផ្សាយពីកម្មវិធីរបស់ខ្លួនដល់សាធារណៈជន អំពីសិទ្ធិ និងករណីយកិច្ចរបស់ពួកគេតាមផ្លូវច្បាប់ និងពីតួនាទីដ៏សំខាន់របស់មេធាវី ក្នុងការការពារសេរីភាពជាសារវ័ន្តរបស់ពួកគេ។ ជនក្រីក្រ និងជនដែលងាយរងគ្រោះផ្សេងទៀត គួរត្រូវបានយកចិត្តទុកដាក់ ជាពិសេស ផ្តល់ជំនួយ ដើម្បីអោយពួកគេ មានលទ្ធភាពអះអាងពីសិទ្ធិរបស់ពួកគេ ហើយនៅពេលដែលចាំបាច់ ត្រូវរកពឹងពាក់ជំនួយពីមេធាវី ។

## ការការពារពិសេសក្នុងរឿងក្តីយុត្តិធម៌ព្រហ្មទណ្ឌ

៥- រដ្ឋាភិបាលនានាត្រូវធានាថា អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងភ្លាមដល់បុគ្គលគ្រប់រូប ពីសិទ្ធិរបស់គេដែលអាចទទួលបានជំនួយពីមេធាវីម្នាក់ តាមការជ្រើសរើសរបស់គេក្រោយពីការចាប់ខ្លួន ឬឃុំខ្លួន ឬនៅពេលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណា១។

៦- ជនណាក៏ដោយដែលមិនមានមេធាវី មានសិទ្ធិទទួលបានមេធាវីម្នាក់ ដែលមានបទពិសោធន៍ និងមានសមត្ថភាពប្រហាក់ប្រហែលទៅនឹងចរិកនៃបទល្មើស ដែលចោទប្រកាន់មកលើខ្លួន ក្នុងគ្រប់រឿងក្តីទាំងអស់ ដែលផលប្រយោជន៍យុត្តិធមិ តំរូវយ៉ាងដូច្នេះ ដើម្បីអោយមេធាវីនោះ ផ្តល់នូវជំនួយផ្នែកច្បាប់ប្រកបដោយប្រសិទ្ធ

ភាព ដោយគ្មានការបង់ថ្លៃ ប្រសិនបើគេមិនមានមធ្យោបាយគ្រប់គ្រាន់ចំណាយលើសេវាកម្មបែបនេះទេ ។

៧- រដ្ឋាភិបាលនានាត្រូវធានាបន្ថែមទៀតថា ជនណាក៏ដោយដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន ទោះជាត្រូវចោទ ឬមិនត្រូវចោទពីបទអាជ្ញាក៏ដោយ ត្រូវមានសិទ្ធិទទួលបានមេធាវីម្នាក់ភ្លាម ក្នុងរឿងក្តីណាក៏ដោយ មិនអោយលើសពីរយៈពេល ៤៨ម៉ោង ក្រោយពេលការចាប់ខ្លួន ឬការឃុំខ្លួននោះឡើយ ។

៨- អ្នកដែលត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬអ្នកជាប់ពន្ធនាគារទាំងអស់ ត្រូវតែបានផ្តល់ឱកាស ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីជួបប្រាស្រ័យទាក់ទង និងប្រឹក្សាយោបល់ជាមួយមេធាវីរបស់ខ្លួន ដោយគ្មានការពន្យាពេល ការរាំងស្ទាក់ ឬការត្រួតពិនិត្យ និងត្រូវតែជាការសំងាត់ទាំងស្រុង ។ មន្ត្រីប្រតិបត្តិច្បាប់ អាចមើលឃើញ តែមិនអាចស្តាប់លឺពីការប្រឹក្សាយោបល់នេះទេ ។

## លក្ខណៈសម្បត្តិ និងការបណ្តុះបណ្តាល

៩- រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវីនានា និងស្ថាប័នអប់រំត្រូវធានាថា មេធាវីត្រូវទទួលបានការអប់រំ និងបណ្តុះបណ្តាលសមស្រប ព្រមទាំងយល់ដឹងពីទស្សនៈនិងតួនាទីតាមបញ្ញត្តិក្រមសីលធម៌

របស់មេធាវី និងយល់ដឹងពីសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត ដែលបានទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ ។

១០- រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវីនានា និងស្ថាប័នអប់រំ ត្រូវធានាថា គ្មានការរើសអើងចំពោះបុគ្គលណាម្នាក់ដែលនឹងចូលប្រកប ឬកំពុងតែប្រកបវិជ្ជាជីវៈច្បាប់នេះ ដោយមូលហេតុ ពូជសាសន៍ ពណ៌សម្បុរ ភេទ ដើមកំណើត ជាតិពន្ធុ សាសនា មតិនយោបាយ ឬការសំដែងមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ប្រភពកំណើត ឋានៈសេដ្ឋកិច្ច ឬឋានៈដទៃទៀតឡើយ លើកលែងតែ លក្ខខណ្ឌតម្រូវឱ្យមេធាវីនោះ ត្រូវតែមានសញ្ជាតិនៃប្រទេសសាម៉ី ទើបមិនត្រូវបានចាត់ទុកថាជាការរើសអើងនោះ ។

១១- នៅប្រទេសនានាដែលមានក្រុមសហគមន៍ ឬតំបន់ដែលសេចក្តីត្រូវការរបស់គេ សំរាប់សេវាកម្មច្បាប់មិនមានដូចបំណង ជាពិសេស ចំពោះក្រុមទាំងឡាយដែលមានវប្បធម៌ ភាសា ឬទំនៀមទំលាប់ផ្សេងៗគ្នា ឬក៏ធ្លាប់ជាជនរងគ្រោះ នៃការរើសអើងកាលពីអតីតកាល រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវីនានា និងស្ថាប័នអប់រំ គួរតែចាត់វិធានការពិសេស ផ្តល់ឱកាសអោយបេក្ខជនដែលមកពីក្រុមទាំងនោះ បានចូលប្រកបវិជ្ជាជីវៈច្បាប់ ហើយត្រូវធានាថាពួកគេទទួលបានការបណ្តុះបណ្តាលសមស្រប ទៅតាមសេចក្តីត្រូវការរបស់ក្រុមគេ ។

## តួនាទី និងការទទួលខុសត្រូវ

១២- មេធាវី ត្រូវរក្សាកិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈរបស់ខ្លួន ជាភ្នាក់ងារដ៏សំខាន់នៃរដ្ឋបាលយុត្តិធម៌ នៅគ្រប់ពេលវេលាទាំងអស់ ។

១៣- តួនាទីរបស់មេធាវីចំពោះកូនក្តីរបស់ខ្លួនត្រូវរួមមានៈ

ក) - ណែនាំកូនក្តី ពីសិទ្ធិ និងករណីយកិច្ចស្របច្បាប់របស់គេ និងពីការងារនៃប្រព័ន្ធច្បាប់ ដែលមានការពាក់ព័ន្ធដល់សិទ្ធិ និងករណីយកិច្ចស្របច្បាប់របស់គេ ចំពោះរឿងក្តី ។

ខ) - ជួយកូនក្តី តាមរាល់មធ្យោបាយដែលសមស្រប និងចាត់ការតាមផ្លូវច្បាប់ ដើម្បីការពារផលប្រយោជន៍របស់គេ ។

គ) - ជួយកូនក្តី នៅចំពោះមុខតុលាការ សាលាក្តី ឬអាជ្ញាធររដ្ឋបាល តាមការសមស្រប ។

១៤- ក្នុងការការពារសិទ្ធិនៃកូនក្តីរបស់ខ្លួន និងក្នុងការលើកស្ទួយបុព្វហេតុនៃយុត្តិធម៌ មេធាវីត្រូវស្វះស្វែងលើកកំពស់សិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត ដែលបានទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ ហើយត្រូវធ្វើការដោយឧស្សាហ៍ព្យាយាម និងដោយសេរី នៅគ្រប់ពេលទាំងអស់ អោយស្របតាមច្បាប់ ព្រមទាំងបទដ្ឋាន និងបញ្ញត្តិក្រមសីលធម៌នៃវិជ្ជាជីវៈច្បាប់ដែលត្រូវបានទទួលស្គាល់ ។

១៥- មេធាវី ត្រូវស្មោះត្រង់ជានិច្ច ក្នុងការគោរពផលប្រយោជន៍របស់កូនក្តីខ្លួន ។

## ការធានាចំពោះដំណើរការមេធាវី

១៦- រដ្ឋាភិបាលត្រូវធានាថា ៖

ក) - មេធាវី អាចបំពេញមុខងារវិជ្ជាជីវៈទាំងអស់របស់ខ្លួន ដោយគ្មានការបំភិតបំភ័យ ការបន្ទុចបង្អាក់ ការយាយី ឬការជ្រៀតជ្រែកដែលមិនត្រឹមត្រូវឡើយ ។

ខ) - មេធាវី អាចធ្វើដំណើរ និងប្រឹក្សាយោបល់ជាមួយកូនក្តីរបស់ខ្លួនបានដោយសេរី ទាំងនៅក្នុងប្រទេស ទាំងនៅបរទេស និង

គ) - មេធាវីមិនត្រូវទទួលរងឬត្រូវបានគំរាមកំហែងដោយការចោទប្រកាន់តាមផ្លូវតុលាការ ឬរដ្ឋបាល ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬទណ្ឌកម្មឯទៀត ចំពោះសកម្មភាពណាមួយដែលខ្លួនបានធ្វើ ស្របតាមបទដ្ឋាន តួនាទី និងបញ្ញត្តិក្រមសីលធម៌វិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ឡើយ ។

១៧- កាលបើ មេធាវី ត្រូវបានគំរាមកំហែងដល់សន្តិសុខ ដោយសារតែការបំពេញតួនាទីរបស់ខ្លួននោះ អាជ្ញាធរត្រូវតែផ្តល់ការការពារអោយបានគ្រប់គ្រាន់ដល់មេធាវីនោះ ។

១៨- មេធាវី មិនត្រូវក្លាយជាមុខសញ្ញាជាមួយកូនក្តីរបស់ខ្លួន ដោយសារតែការបំពេញតួនាទីរបស់ខ្លួន អោយកូនក្តីនោះឡើយ ។

១៩- គ្មានតុលាការ ឬអាជ្ញាធររដ្ឋបាលណា ដែលបានទទួលស្គាល់សិទ្ធិមានស្មាក្តីហើយ បែរជាបដិសេធឈប់ទទួលស្គាល់នូវសិទ្ធិមានមេធាវីនៅចំពោះមុខសមត្ថកិច្ចខ្លួននោះឡើយ លុះត្រាតែមេធាវីនោះ មិនបានបំពេញលក្ខខណ្ឌស្របតាមច្បាប់ជាតិ និងការអនុវត្តន៍ជាក់ស្តែង ហើយមិនស្របជាមួយនឹងគោលការណ៍នេះ ។

២០- មេធាវីត្រូវមានអភ័យឯកសិទ្ធិពីបទព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ចំពោះសារណាការពារពាក់ព័ន្ធនានា ដែលធ្វើក្នុងបំណងសុចរិតក្នុងការការពារ ទោះជាលាយលក្ខណ៍អក្សរក្តី ជាផ្ទាល់មាត់ក្តី ឬក្នុងការបង្ហាញខ្លួន ជាវិជ្ជាជីវៈរបស់ខ្លួន នៅចំពោះមុខតុលាការសាលាក្តី ឬអាជ្ញាធរច្បាប់ ឬរដ្ឋបាលផ្សេងទៀត ។

២១-អាជ្ញាធរមានសមត្ថកិច្ចមានតួនាទីត្រូវធានាអោយមេធាវីមានសិទ្ធិទទួលបានព័ត៌មានដែលសមស្រប សំណុំរឿង និងឯកសារនៅក្នុងការកាន់កាប់ ឬការគ្រប់គ្រងរបស់ខ្លួន អោយមេធាវីមានពេលវេលាគ្រប់គ្រាន់ អាចផ្តល់ជំនួយផ្នែកច្បាប់ដល់កូនក្តីរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព ។ សិទ្ធិទទួលបាននេះ គួរតែផ្តល់អោយនៅពេលវេលាដ៏សមស្របឆាប់បំផុត ។

២២- រដ្ឋាភិបាលនានា ត្រូវគោរព និងទទួលស្គាល់ថា រាល់ទំនាក់ទំនង និងរាល់ការប្រឹក្សាយោបល់រវាងមេធាវី និងកូនក្តីរបស់ខ្លួនក្នុងទំនាក់ទំនងវិជ្ជាជីវៈ គឺជាការសំងាត់។

## សេរីភាពនៃការសំដែងមតិ និងសេរីភាពនៃការបង្កើតសមាគម

២៣- មេធាវី ក៏ដូចជាប្រជាពលរដ្ឋដែរ មានសិទ្ធិទទួលបានសេរីភាពនៃការសំដែងមតិ ជំនឿ ការបង្កើតសមាគម និងការជួបប្រជុំ។ ជាពិសេស មេធាវីត្រូវមានសិទ្ធិចូលរួមជាសាធារណៈក្នុងការពិភាក្សាបញ្ហាច្បាប់ រដ្ឋបាលយុត្តិធម៌ និងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ព្រមទាំងចូលរួម ឬបង្កើតជាអង្គការតាមមូលដ្ឋានអង្គការជាតិ និងអន្តរជាតិ ក៏ដូចជាចូលរួមការប្រជុំរបស់ខ្លួន ដោយមិនទទួលរងនូវការរឹតត្បិតវិជ្ជាជីវៈ ដោយហេតុផលនៃសកម្មភាពស្របច្បាប់ ឬសមាជិកភាពរបស់ខ្លួន នៅក្នុងអង្គការស្របច្បាប់មួយ។ ក្នុងការអនុវត្តន៏សិទ្ធិទាំងនេះ ជានិច្ចកាល មេធាវី ត្រូវតែធ្វើខ្លួនឱ្យស្របតាមច្បាប់ ព្រមទាំងបទដ្ឋាន និងបញ្ញត្តិក្រមសីលធម៌វិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់។

## សមាគមវិជ្ជាជីវៈមេធាវី

២៤- មេធាវីត្រូវមានសិទ្ធិបង្កើត និងចូលរួមសមាគមវិជ្ជាជីវៈដែលគ្រប់គ្រងដោយខ្លួនឯងដើម្បីតំណាងអោយផលប្រយោជន៏របស់

ខ្លួន លើកស្ទួយការបណ្តុះបណ្តាល និងការអប់រំបន្ត និងដើម្បីការពារបូរណភាពវិជ្ជាជីវៈរបស់ខ្លួន។ អង្គភាពប្រតិបត្តិនៃសមាគមវិជ្ជាជីវៈ ត្រូវតែធ្វើការបោះឆ្នោតដោយសមាជិករបស់ខ្លួន និងត្រូវអនុវត្តតួនាទីរបស់ខ្លួនដោយគ្មានការជ្រៀតជ្រែកពីខាងក្រៅ។

២៥- សមាគមវិជ្ជាជីវៈមេធាវីត្រូវសហការជាមួយរដ្ឋាភិបាល ដើម្បីធានាថាបុគ្គលគ្រប់រូបមានសិទ្ធិទទួលបានស្មើភាពគ្នា និងប្រកបដោយប្រសិទ្ធភាពពីសេវាកម្មច្បាប់ ហើយធានាថាមេធាវីអាចប្រឹក្សាយោបល់ និងជួយកូនក្តីរបស់ខ្លួនបាន ស្របតាមច្បាប់ និងបទដ្ឋាន និងបញ្ញត្តិក្រមសីលធម៌វិជ្ជាជីវៈ ដែលត្រូវបានទទួលស្គាល់ដោយគ្មានការជ្រៀតជ្រែកមិនត្រឹមត្រូវឡើយ ។

## ចំណាត់ការដាក់វិន័យ

២៦- ក្រមសីលធម៌វិជ្ជាជីវៈមេធាវី ត្រូវតែបង្កើតឡើងដោយវិជ្ជាជីវៈច្បាប់ តាមរយៈអង្គភាពដ៏សមស្របរបស់ខ្លួន ឬដោយច្បាប់អនុលោមតាមច្បាប់ជាតិ និងប្បវេណី ព្រមទាំងបណ្តាវិធាន និងបទដ្ឋានអន្តរជាតិដែលត្រូវបានទទួលស្គាល់ ។

២៧- ការចោទប្រកាន់ ឬបណ្តឹងចំពោះមេធាវី ស្ថិតក្នុងសមត្ថកិច្ចវិជ្ជាជីវៈរបស់ខ្លួន ត្រូវតែចាត់ការអោយបានឆាប់រហ័ស និងត្រឹមត្រូវ តាមនីតិវិធីដែលសមស្រប។ មេធាវី ក៏ត្រូវមានសិទ្ធិទទួលបាន

នូវការជំនុំជំរះប្រកបដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានជំនួយពីមេធាវីម្នាក់ទៀត តាមការជ្រើសរើសរបស់គេ។

២៨- ចំណាត់ការដាក់វិន័យចំពោះមេធាវីត្រូវតែធ្វើនៅចំពោះមុខគណៈកម្មាធិការវិន័យឥតលំអៀងមួយ ដែលបង្កើតឡើងដោយវិជ្ជាជីវៈច្បាប់ នៅចំពោះមុខអាជ្ញាធរឯករាជ្យមួយដែលបង្កើតដោយលក្ខន្តិកៈ ឬនៅចំពោះមុខតុលាការ និងត្រូវតែស្ថិតក្រោមការត្រួតពិនិត្យនីត្យានុកូលភាពដោយឯករាជ្យពីតុលាការ។

២៩- រាល់ចំណាត់ការដាក់វិន័យ ត្រូវតែសំរេចស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទដ្ឋាន និងបញ្ញត្តិក្រមសីលធម៌វិជ្ជាជីវៈដទៃទៀត ដែលត្រូវបានទទួលស្គាល់ ព្រមទាំងតាមស្មារតីនៃគោលការណ៍នេះ។